ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងរដ្ឋប្បវេណី ៣៣៣✱៣៣

លេខៈ ៤១៤

ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៣

**នាមនាមប្រជារាស្ត្រខ្មែរ**

**តុលាការកំពូល**

<u>សាលដីកា</u>

លេខៈ ១៨០ បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០០៤

ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០០៤ ដោយមានសមាសភាពដូចតទៅ :

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **ឃីម** | **ប៊ុន្ណុ** | ជាប្រធានក្រុមប្រឹក្សាជំនុំជំរះ |
| ២-លោក | ស៊ិន | ឌីម | ជាចៅក្រម |
| ៣-លោក | ប្រាក់ | គឹមសាន | ជាចៅក្រមរបាយការណ៍ |
| ៤-លោក | ជីវ | កេង | ជាចៅក្រម |
| ៥-លោក | ម៉ុង | មុន្នីចរិយា | ជាចៅក្រម |
| លោក | **សុខ** | **ម៉ៅ** | ក្រឡាបញ្ជី |

តំណាងមហាអយ្យការ

| | | | |
|---|---|---|---|
| លោក | **ឈួន** | **ចាន់ថា** | ជាព្រះរាជអាជ្ញា |

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីការដ្ឋប្បវេណីលេខ៨៦"គ" ចុះថ្ងៃទី ២៨ ខែឧសភា ឆ្នាំ២០០៣ នៃសំណុំរឿងរដ្ឋប្បវេណីលេខ២១៨ ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍រវាង :

ដើមចោទឈ្មោះ**ស៊ុម** **ឡី**(ជាចុងបណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៤៥ឆ្នាំ ជាតិខ្មែរឥស្លាម ទីលំនៅសព្វថ្ងៃ ភូមិជើងភ្លើង ឃុំស្លាមព្រះ ស្រុកបាកាន ខេត្តពោធិសាត់ ។ឳពុកឈ្មោះស៊ុម "ស" ម្តាយឈ្មោះទះ ប្រពន្ធឈ្មោះវៀត ទះ មានកូន៥នាក់ ។

ចុងចម្លើយឈ្មោះ **ម៉ាន** **យ៉េត** (ជាម្ចាស់បណ្តឹងសាទុក្ខ)ភេទប្រុស អាយុ៤៨ឆ្នាំ ជាតិខ្មែរឥស្លាម មុខរបរ រោងម៉ាស៊ីនកិនស្រូវ ទីលំនៅសព្វថ្ងៃភូមិជើងភ្លើង ឃុំស្លាមព្រះ ស្រុកបាកាន ខេត្តពោធិសាត់ ។ ឳពុកឈ្មោះតា ម៉ាន "រ" ម្តាយឈ្មោះលស់ ស៊ុំ "រ" ប្រពន្ធឈ្មោះសាទះ ។

មានមេធាវីលោក តែ ចំណាន ។

<u>**ចម្មវត្ថុរឿង**</u> : ប្តឹងឱ្យចុងចម្លើយរុះរើរោងម៉ាស៊ីនស្រូវចេញពីដីកម្មសិទ្ធិ

បានឃើញបណ្តឹងសាទុក្ខលេខ២២៦ ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៣ របស់ឈ្មោះម៉ាន យ៉េត ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៨៦"គ" ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៣...

របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចសេចក្ដីសំរេចនៃសាលដីកាទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ៤១៤ ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៣ របស់តុលាការកំពូល ។

តាមពាក្យបណ្ដឹងចុះថ្ងៃទី០៧-០២-១៩៩៩ របស់ឈ្មោះស៊ឹម ឡី ប្ដឹងពីឈ្មោះម៉ាន់ យ៉េត ឱ្យរុះរើរោងម៉ាស៊ីនកិនស្រូវចេញពីដីកម្មសិទ្ធិដោយហេតុថា នៅក្នុងអំឡុងឆ្នាំ១៩៩៤ ឈ្មោះស៊ឹម ឡី និងខ្លួនបានហ៊ុនគ្នាទិញម៉ាស៊ីនកិនស្រូវរកស៊ីជាមួយគ្នាបានរយៈពេលប្រហែលជា០៥ឆ្នាំ ក៏កើតមានទំនាស់គ្នា ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ៨៩ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០១ របស់តុលាការខេត្តពោធិសាត់ ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្ដឹងចុះថ្ងៃទី០៧-០២-១៩៩៩ របស់ដើមចោទ ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២-ទទួលស្គាល់ប័ណ្ណសិគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ D៨-១៣៨១ ចុះថ្ងៃទី១៨-៨-១៩៩៤ របស់សុរិយោដីខេត្តពោធិសាត់ ដែលបានប្រគល់កម្មសិទ្ធិកាន់កាប់ដីឱ្យឈ្មោះស៊ឹម ឡី និងនាងវើត នះ តាមច្បាប់ ។

៣-បង្គាប់ឱ្យឈ្មោះម៉ាន យ៉េត រុះរើម៉ាស៊ីនកិនស្រូវចេញផុតពីដីដែលជាកម្មសិទ្ធិរបស់ឈ្មោះស៊ឹម ឡី និងនាងវើត នះ ដែលស្ថិតនៅក្នុងភូមិជើងភ្លើង, ឃុំស្នាមព្រះ ស្រុកបាកានខេត្តពោធិសាត់ ក្រោយសាលក្រមចូលជាស្ថាពរ ។ ក្នុងករណីឈ្មោះម៉ាន យ៉េត រឹងទទឹងមិនព្រមរុះរើម៉ាស៊ីនកិនស្រូវចេញពីលើដីកម្មសិទ្ធិរបស់ឈ្មោះស៊ឹម ឡី ទេ អាជ្ញាធរមានសមត្ថកិច្ចត្រូវប្រើកំលាំងរុះរើដោយឱ្យឈ្មោះម៉ាន យ៉េត ចេញសោហ៊ុយបង់ខាតតាមកំលាំងពលកម្មជាក់ស្ដែង ។

៤-បង្គាប់ឱ្យឈ្មោះម៉ាន យ៉េត បង់ប្រាក់ប្រដាប់ក្ដីគឺពន្ធចុះបញ្ជីក្ដី និងពន្ធហ្វ៊ីង ១៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់២០០៛ ប្រាក់ចំណាយក្នុងការស៊ើបសួរ ៥.០០០៛ ប្រាក់នេះត្រូវរឹបអូសទុករួចជាស្រេច ។ កាលបើប្ដឹងឧទ្ធរណ៍ឱ្យឈ្មោះម៉ាន យ៉េត បង់ពន្ធសមាមាត្រ១%លើទំហំដីដែលមានទំនាស់ទាំងមូល ប្រាក់នេះបង់ចូលថវិការដ្ឋ ៨០% សំរាប់រង្វាន់ក្រឡាបញ្ជីទូទាំងព្រះរាជាណាចក្រកម្ពុជា ២០% បន្ថែមទៀត ។

៥-សាលក្រមនេះ ជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូក្ដី បើភាគីណាមិនសុខចិត្ត មានសិទ្ធិប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់ពីរខែគត់ ចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ។

បានឃើញបណ្ដឹងឧទ្ធរណ៍លេខ ២៦ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០១ របស់ឈ្មោះម៉ានយ៉េត ប្ដឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ៨៩ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០១ របស់តុលាការខេត្តពោធិសាត់ ត្រង់ចំណុចនៃសាលក្រមទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ១២៧"គ" ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០០២ របស់...

សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

១-ទទួលបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី២៣-១១-២០០១ របស់ឈ្មោះម៉ាន់ យ៉េត ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែលើកចោលដោយទាស់នឹងគតិច្បាប់ ។

២-តំកល់សាលក្រមរដ្ឋប្បវេណីលេខ ៨៩ ចុះថ្ងៃទី ២០-១១-២០០១ របស់តុលាការខេត្តពោធិសាត់ ទុកជាបានការដដែល ។

៣-កាត់យកប្រាក់ប្រដាប់ក្ដីជាន់សាលាឧទ្ធរណ៍ចំនួន ១៣.០០០រៀល ដែលដើមចោទបានបង់រួចហើយ គឺពន្ធចុះបញ្ជីក្ដី និងពន្ធហ្វ៊ីងចំនួន ២៩៥០៖ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០៖ ចំណាយលើកិច្ចប្រគល់ដីកាកោះ ៥.០០០៖ និងចំណាយលើអាជ្ញាធរតុលាការ ៥.០០០៖ ។ នៅពេលដែលសាលដីកានេះចូលជាស្ថាពរឱ្យចុងចម្លើយសងប្រាក់១៣.០០០រនេះទៅដើមចោទវិញ។

៤-សាលដីកានេះ ជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខដើមចោទ និងមេធាវីដើមចោទ កំបាំងមុខចុងចម្លើយ ។ បើកផ្លូវតវ៉ាក្នុងកំណត់ច្បាប់ ។

បានឃើញបណ្ដឹងទាស់លេខ ១៥៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០២ របស់ឈ្មោះម៉ាន់ យ៉េត ប្ដឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ១២៧"គ" ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចទាំងមូលនៃសេចក្ដីសំរេច ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៨៦"គ" ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្ដឹងទាស់ចុះថ្ងៃទី ១៦-១០-២០០២ របស់ឈ្មោះម៉ាន់ យ៉េត ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តម្កល់សាលដីកាកំបាំងមុខលេខ ១២៧"គ" ចុះថ្ងៃទី១០-១០-២០០២ របស់សាលាឧទ្ធរណ៍ទុកជាបានការដដែល ។

សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូក្ដីនិងចំពោះមុខមេធាវីគូក្ដី ។

បើកផ្លូវប្ដឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្ដឹងសាទុក្ខលេខ២២៦ ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៣ របស់ឈ្មោះម៉ាន យ៉េត ប្ដឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៨៦"គ" ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចសេចក្ដីសំរេចនៃសាលដីកាទាំងមូល ។

បានឃើញសារណាការពារ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០០៣ របស់ឈ្មោះម៉ាន់ យ៉េត ។

បានឃើញសារណាតប ចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ២០០៣ របស់ឈ្មោះស៊ឹម ឡី ។

បានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា : សាលាឧទ្ធរណ៍បានសំរេចខុសឆ្គងគតិច្បាប់ សូមក្រុមប្រឹក្សាជំនុំជំរះ សំរេចតាមច្បាប់ ៕

បានស្តាប់ចម្លើយរបស់ឈ្មោះ ម៉ាន យ៉េត នាពេលសវនាការថា : សាលាឧទ្ធរណ៍កាត់មិនត្រឹមត្រូវមូលហេតុដីរោងម៉ាស៊ីន ខ្លួនបានទិញពីឈ្មោះស៊ឹម វណ្ណ ហើយស៊ឹម វណ្ណា លក់ភាគហ៊ុនឱ្យស៊ឹម ឡី ក្រោយមកស៊ឹម ឡី លក់ភាគហ៊ុនមកឱ្យខ្លួនទៀត ហេតុនេះ ដីនិងរោងម៉ាស៊ីនជាកម្មសិទ្ធិរបស់ខ្លួន ព្រោះក្រោយទិញភាគហ៊ុនពីស៊ឹម ឡី ហើយ ស៊ឹម ឡី បានទៅធ្វើរោងម៉ាស៊ីនមួយទៀតនៅកន្លែងផ្សេងៗ ហើយខ្លួនបានរុះរោងកតូច ធ្វើរោងម៉ាស៊ីនធំ លើទីតាំងដដែល គ្រាន់តែ ខ្លួនយកឈើដាក់លើទីស្នាក់ការភូមិបន្តិចពេលរៀបចំធ្វើរោងថ្មី ស៊ឹម ឡី ដើរបំផុសនាំគេធ្វើបាតុកម្មប្រុងបំផ្លាញ ខ្លួនសូមបដិសេធសវិរេចរបស់សាលាឧទ្ធរណ៍ ។

បានស្តាប់ចម្លើយរបស់ឈ្មោះ ស៊ឹម ឡី នាពេលសវនាការថា :ម៉ាន យ៉េត បានទិញភាគហ៊ុនពីរោងម៉ាស៊ីនស្រូវពីស៊ឹម វ៉ាន់ ដូចគ្នា ក្រោយពេលខ្លួនលក់ឱ្យម៉ាន យ៉េត ហើយ (ភាគហ៊ុន) ខ្លួនបានចេញទៅសង់រោងម៉ាស៊ីនថ្មីកន្លែងផ្សេងរួចហើយ នៅចំងាយពីរោងចាស់ប្រហែល ៥០ម៉ែត្រប៉ុណ្ណោះ ។ ម៉ាន យ៉េត ក្រោយទិញភាគហ៊ុនពីខ្លួនបានហើយ គាត់រុះរោងចាស់ធ្វើរោងម៉ាស៊ីនថ្មីត្រង់កន្លែងចាស់ដដែល ដំបូងម៉ាន យ៉េតប្រុងធ្វើលើដីស្នាក់ការភូមិនៅជិតដីទំនាស់ទេ ដោយសារខ្លួនដើរប្រាប់អ្នកភូមិទៅគេបះបោរមិនឱ្យធ្វើ ម៉ាន យ៉េត បែរជាមកធ្វើលើដីខ្លួនទេវិញ ។ សូមឱ្យម៉ាន យ៉េតរុះរោងចេញពីដីរបស់ខ្លួន ព្រោះមានប័ណ្ណកម្មសិទ្ធិហើយ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកតែ ចំណាន ជាមេធាវីការពារឱ្យចុងចម្លើយបានលើកឡើងថា : ខ្លួនជាមេធាវីឱ្យឈ្មោះម៉ាន យ៉េត បើស្តាប់ចំលើយរបស់ម៉ាន យ៉េត ឃើញថា ពិរោះណាស់ តែមានចំណុចគួរពិចារណា ចំពោះរឿងនេះខ្លួនយល់ថា អាត់ ជួង គឺ ស៊ឹម វ៉ាន់ កន្លងមកខ្លួនបានជួបស៊ឹម វ៉ាន់ ដើម្បីយកចម្លើយស៊ឹម វ៉ាន់ មិនព្រមឆ្លើយសោះ ដោយគាត់ថាភាគីទាំងពីរសុទ្ធតែបងប្អូន ខ្លួនយល់ថា មានអាថ៌កំបាំងមិនខាន តុលាការគួរយកចំលើយស៊ឹម វ៉ាន់ផង ម្យ៉ាងទៀតបើមានចំលើយដូចពេលនេះ ខ្លួនយល់ថា ប្រហែលសាលាឧទ្ធរណ៍មិនសំរេចឱ្យស៊ឹម ឡី ឈ្នះទេ ។ ស៊ឹម ឡី គាត់ថាទិញភាគហ៊ុនពីស៊ឹម វណ្ណ ចុះហេតុអ្វីបានជាទៅផ្ទេរសិទ្ធិពីអ្នកផ្សេងទេវិញ ក្រោយមកមានការបញ្ជាក់របស់អ្នកផ្ទេរសិទ្ធិថា ស្នាមមេដៃផ្ទេរសិទ្ធិនោះមិនមែនរបស់ខ្លួនទៀត នៅតុលាការខេត្តស៊ឹម ឡី ឆ្លើយថា ខ្លួនទិញតែភាគហ៊ុនទេ ក្រោយមកលក់បន្តឱ្យម៉ាន់ យ៉េត ហើយបែរជាឆ្លៀតឱកាសម៉ាន យ៉េត គ្រោះថ្នាក់ចរាចរ ស៊ឹម ឡី រត់ធ្វើប័ណ្ណកម្មសិទ្ធិដោយលួចលាក់តែម្តង ឯលិខិតមានបោះត្រាពីរផ្សេងគ្នា ច្បាស់ជាមានត្រាណាមួយអស់សុពលភាពមិនខាន ខ្លួនសូមអះអាងថា ដីនេះពិតជាដីស្របច្បាប់របស់ឈ្មោះម៉ាន យ៉េត ពិតមែន សូមបង្វិលសំណុំរឿងដើម្បីសាលាឧទ្ធរណ៍ជំនុំជំរះឡើងវិញ ឱ្យត្រឹមត្រូវតាមគតិច្បាប់ ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចំលើយគូភាគី និង សេចក្តីសន្និដ្ឋានការពាររបស់មេធាវីចុងចម្លើយ...

- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

**តុលាការកំពូល**

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ២២៦ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៣ របស់លោក ម៉ាន យ៉េត ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា ការដែលតុលាការខេត្តពោធិសាត់ និងសាលាឧទ្ធរណ៍សំរេចប្រគល់ដីទំនាស់ឱ្យដើមចោទដោយអាងហេតុថា នៅឆ្នាំ១៩៨៤ ដើមចោទបានបបួលចុងចម្លើយចូលហ៊ុនគ្នារកស៊ីកិនស្រូវ ហើយថាដើមចោទបានលក់តែហ៊ុនម៉ាស៊ីនស្រូវ ពុំបានលក់ដីទេនោះជាការសំរេច ពុំមានសំអាងហេតុត្រឹមត្រូវទេ ពីព្រោះថា :

. នៅពេលសវនាការនេះ លោក ស៊ឹម ឡី បានទទួលស្គាល់ថាលោក និងចុងចម្លើយសុទ្ធតែទិញភាគហ៊ុនលោកស៊ឹម វ៉ាន់ ដូចគ្នា ប៉ុន្តែតុលាការពុំបានកោះហៅឈ្មោះស៊ឹម វ៉ាន់ មកបំភ្លឺតុលាការទេ ។

ក្រោយពេលលក់ភាគហ៊ុនឱ្យចុងចម្លើយហើយ ដើមចោទបានទៅសង់រោងម៉ាស៊ីនថ្មីនៅកន្លែងផ្សេងទៀតហើយ ។ ហើយតាមកំណត់ហេតុចុះថ្ងៃទី១១-០១-១៩៩៩ របស់មន្ទីរឧស្សាហកម្មខេត្តពោធិសាត់ ក៏ពុំបានបញ្ជាក់ឱ្យបានច្បាស់លាស់ពីដីទំនាស់នេះដែរ

- យល់ឃើញថា តាមលិខិតផ្ទេរសិទ្ធិចុះថ្ងៃទី២៩-៨-១៩៨៤ ឈ្មោះគង់ ហុក, គង់មួយ គីម ពាក់ ,ម៉ាន់ ឃៀង និងស្វាយធីម បានផ្ទេរសិទ្ធិភាគហ៊ុនអាជីវកម្មម៉ាស៊ីនកិនស្រូវឱ្យលោក ស៊ឹម ឡី ប៉ុន្តែលោកស៊ឹម ឡី បានលើកឡើងនៅពេលសវនាការនេះថា លោកស៊ឹម វ៉ាន់ទេ ជាអ្នកលក់ភាគហ៊ុនឱ្យលោក ។ ម្យ៉ាងទៀត តាមលិខិតបំភ្លឺចុះថ្ងៃទី២៩-៤-១៩៩៩ របស់ឈ្មោះវេង ហុក និងលិខិតចុះថ្ងៃគ្មានខែ គ្មានឆ្នាំ ១៩៩៩របស់លោក ម៉ាន់ ឃៀង បញ្ជាក់ថា ស្នាមមេដៃលើលិខិតផ្ទេរសិទ្ធិចុះថ្ងៃទី២៩-៤-១៩៩៩ ពុំមែនស្នាមមេដៃលោកទេ ហើយតាមលិខិតបំភ្លឺចុះថ្ងៃទី០៥-៥-១៩៩៩ របស់ឈ្មោះស្វាយ ធីម ថា លោកលក់រោងម៉ាស៊ីនតម្លៃ ៨.៥តម្លឹងមាស គឺលក់ទាំងម៉ាស៊ីន ទាំងដីឱ្យលោក ស៊ឹម វ៉ាន់ ។

ដូច្នេះមុននឹងសំរេចសេចក្តី គប្បីធ្វើការស៊ើបអង្កេតឱ្យបានច្បាស់លាស់ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ៨៦"គ" ចុះថ្ងៃទី២៩-០៥-២០០៣ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានការខុសឆ្គងទាំងទំរង់ ទាំងគតិច្បាប់ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី ទំលោះចុងក្តី**

១-ទទួលបណ្តឹងសាទុក្ខលេខ២២៦ ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៣ របស់...

លោក ម៉ាន់ យ៉េត ទុកជាត្រឹមត្រូវទាំងទំរង់ ទាំងគតិច្បាប់ ។

២-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ៨៦"គ" ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ ២០០៣ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ ៤១៤ ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៣ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីដែលលោក ស៊ឹម ឡី បានបង់រួចហើយនៅតុលាការ កំពូល ចំនួន១៩.០០០៛ គឺ:

-ពន្ធចុះបញ្ជីក្តី និងពន្ធហ្វ៊ីងចំនួន ៤.០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០៛ សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ។

-ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០៛ សរុប ១៩.០០០រៀល ។

៥-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី ១៦ ខែសីហា ឆ្នាំ២០០៤៕